# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
លេខ: ១៣៤ ល.ភ.ណ

ថ្ងៃពុធ ៨រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៤

## សេចក្តីជូនដំណឹង
## ស្តីពី
## ការអញ្ជើញចូលរួមដេញថ្លៃ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ នឹងដាក់ឲ្យដេញថ្លៃ ជាសាធារណៈ ដើម្បីផ្គត់ផ្គង់នូវទំនិញ ដូចខាងក្រោម:

១-កញ្ចប់"ក": ការផ្គត់ផ្គង់គ្រឿងបន្លាស់ប្រព័ន្ធមេកានិច

២-កញ្ចប់"ខ": ការផ្គត់ផ្គង់កុំព្យូទ័រ និងសម្ភារបរិក្ខារព័ត៌មានវិទ្យា

ឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ (រួមទាំងសេចក្តីណែនាំ) មានដាក់លក់នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ដែលមានអាសយដ្ឋានលេខ៤៥ ផ្លូវលេខ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ចាប់ពីថ្ងៃសុក្រ ទី២៧ ខែកញ្ញា ឆ្នាំ២០២៤ តទៅ រៀងរាល់ម៉ោងធ្វើការ (៨:០០នាទី ដល់១៦:៣០នាទី) ដល់ថ្ងៃពុធ ទី៣០ ខែតុលា ឆ្នាំ២០២៤ ត្រឹមវេលាម៉ោង ១៦:០០នាទី ក្នុងមួយច្បាប់តម្លៃ ១៦០,០០០រៀល សម្រាប់កញ្ចប់"ក" និង៣០០,០០០រៀល សម្រាប់កញ្ចប់"ខ"។

កាលបរិច្ឆេទបង្ហាញគ្រឿងបន្លាស់ប្រព័ន្ធមេកានិច ថ្ងៃសុក្រ ទី១៨ ខែតុលា ឆ្នាំ២០២៤ វេលាម៉ោង ០៩:០០នាទី។ ការដែលមិនបានចូលរួមពិនិត្យនូវគ្រឿងបន្លាស់ប្រព័ន្ធមេកានិច គឺជាការទទួលខុសត្រូវរបស់អ្នកចូលរួមដេញថ្លៃផ្ទាល់។

កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃគឺ ថ្ងៃព្រហស្បតិ៍ ទី៣១ ខែតុលា ឆ្នាំ២០២៤ កញ្ចប់"ក" វេលាម៉ោង ១៥:០០នាទី និងកញ្ចប់"ខ"វេលាម៉ោង១៥:១៥នាទី, នៅអង្គភាពលទ្ធកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ជាន់ទី១) តាមអាសយដ្ឋានខាងលើ។

គ្រប់ពាក្យដេញថ្លៃទាំងអស់ ត្រូវភ្ជាប់មកជាមួយនូវប្រាក់កក់ធានាការដេញថ្លៃដែលមានចំនួនដូចបានកំណត់ក្នុងឯកសារដេញថ្លៃ។

អ្នកដេញថ្លៃមានសិទ្ធិជ្រើសរើសកញ្ចប់មួយ ឬទាំងអស់។ ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ (ទូរស័ព្ទទាក់ទងលេខ ០១៧ ៨១១ ៩១១)។

ជ. គណៈកម្មាធិការលទ្ធកម្ម
អនុប្រធាន

ជូ ផល្លា

ចម្លងជូន៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
"ដើម្បីជ្រាបជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ